**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**

**អគ្គនាយកដ្ឋានស្រាវជ្រាវ**

**នាយកដ្ឋានស្រាវជ្រាវថវិកា**

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖


- គម្រោងក្រៅតំបន់សេដ្ឋកិច្ចពិសេសធ្លាក់ចុះជិត ៣០%
- អគ្គទេសាភិបាល NBC សរសើរកិច្ចប្រឹងប្រែងធនាគារកណ្តាលក្នុងការរក្សាស្ថិរភាពសន្ទនិយភាពហិរញ្ញវត្ថុ
- តើកម្ពុជាអាចឈានទៅបើកប្រទេសទាំងស្រុងតាមផែនការកំណត់របស់រដ្ឋាភិបាលដែរ ឬយ៉ាងណា ?
- កសិករក្រីក្រប្រមាណ៩០០គ្រួសារ ទទួលបានពូជមាន់ កង្កែប និងត្រី ពីមន្ទីរកសិកម្មខេត្តឧត្តរមានជ័យ
- កិច្ចពិភាក្សាតុមូលថ្នាក់រដ្ឋមន្ត្រី ក្រោមប្រធានបទ ស្តីពី “ការប្រើប្រាស់បច្ចេកវិទ្យាទំនើប ដើម្បីវិបុលភាពរួម
- ពាណិជ្ជកម្មរបស់ម៉ាឡេស៊ីនៅក្នុងខែសីហា ឆ្នាំ២០២១
- ឱនភាពពាណិជ្ជកម្មវៀតណាម សម្រាប់ពាក់កណ្តាលចុងខែ នៃខែសីហា ឆ្នាំ២០២១
- រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុប្រទេសឥណ្ឌូនេស៊ី មើលឃើញឱនភាពថវិកាឆ្នាំ២០២១ទាបជាង៥,៤%នៃផ.ស.ស
- រោងចក្រកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង វៀតណាម ជាង៦៨% ទទួលរងការលុបចោលការបញ្ជាទិញ និងការពិន័យជាប្រាក់
- សហភាពអឺរ៉ុប គ្រោងផ្តល់ជំនួយឥតសំណងជាង ១៧លានដុល្លារ ដើម្បីអភិវឌ្ឍវិស័យកសិកម្មកម្ពុជា
- បំណុលរបស់ប្រទេសក្រីក្រ កើនឡើង ១២% ស្មើនឹង ៨៦០ប៊ីលានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០២០ យោងតាមធនាគារពិភពលោក
- អាមេរិក អំពាវនាវឱ្យអង្គការ OPEC+ ធ្វើការបន្ថែមទៀតពាក់ព័ន្ធនឹងតម្លៃប្រេងឆៅ



ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២១ លេខ ៖ ៨៩

# ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

## គម្រោងក្រៅតំបន់សេដ្ឋកិច្ចពិសេសធ្លាក់ចុះជិត ៣០%




*ប្រភព៖ Heng Chivoan, Khmer Times ២០២១*

គម្រោងវិនិយោគឯកជនចំនួន ៧៥ នៅក្រៅតំបន់សេដ្ឋកិច្ចពិសេស (SEZ) ត្រូវបានអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ក្នុងរយៈពេល ៨ ខែដំបូងនៃឆ្នាំ ២០២១ ធ្លាក់ចុះជិត ៣០% បើធៀបរយៈពេលដូចគ្នានៃឆ្នាំមុន នេះបើយោងតាមរបាយការណ៍ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

របាយការណ៍នេះបានបង្ហាញពី ទិដ្ឋភាពទូទៅសម្រាប់ការវិនិយោគថ្មី នៅក្នុងគម្រោងមិនមែនតំបន់សេដ្ឋកិច្ចពិសេស ដែលបានអនុម័តដោយ CDC ពីខែមករាដល់ខែសីហា ជាមួយនឹងដើមទុនសរុបដែលមានតម្លៃ ១,១០៦ ប៊ីលានដុល្លារ ធ្លាក់ចុះ ៥២,៥% និងបង្កើតការងារចំនួន ៥៧ ០០០កន្លែង ដែលធ្លាក់ចុះ ៣២,៣% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

តាមរយៈ លោក **លឹម ហេង** អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា ការធ្លាក់ចុះនៃគម្រោងថ្មីៗគឺដោយសារការរឹតត្បិតទប់ស្កាត់កូវីដ-១៩ ទាក់ទងនឹងចលនាមនុស្សឆ្លងដែនរួមបញ្ចូលរយៈពេលវែងនៃការធ្វើចត្តាឡីស័ក ដែលរារាំងដំណើរការនៃការសិក្សាទីផ្សារ និងការជ្រើសរើសទីកន្លែងសម្រាប់ការបណ្តាក់ទុនដែលមានសក្តានុពល ដែលជាលទ្ធផលរារាំងដល់ដំណើរការវិនិយោគ។

ទោះបីជាយ៉ាងណា កម្ពុជាត្រូវបានគេរំពឹងថានឹងបើកដំណើរការសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ ក្នុងពេលឆាប់ៗនេះ និងកាត់បន្ថយរយៈពេលចត្តាឡីស័កថ្មីមកត្រឹមតែ រយៈពេល៧ថ្ងៃ ហើយការរំពឹងទុកនៃការកើនឡើងនៃការវិនិយោគនេះ នឹងកាន់តែលេចឡើងនៅដើមឆ្នាំក្រោយ នៅពេលដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងតំបន់ និងទ្វេភាគីជាច្រើនត្រូវបានកំណត់ឱ្យចូលជាធរមាន។

ដោយឡែក តាមរយៈអ្នកអង្កេតការ វិស័យមួយចំនួនដែលកំពុងជាប់គាំងក្នុងកំឡុងពេលកូវីដ នឹងចាប់ផ្តើមរីកចម្រើនឡើងវិញក្នុងពេលឆាប់ៗនេះផងដែរ ដូចជា វិស័យទេសចរណ៍ ឧស្សាហកម្ម អចលនទ្រព្យ និងសំណង់ និងបច្ចេកវិទ្យា ជាដើម។

*ដោយ វត្តា វង្សវឌ្ឍនៈ*

*ប្រភព៖ Phnom Penh Post ចេញផ្សាយថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១*

## អគ្គទេសាភិបាលNBC សរសើរកិច្ចប្រឹងប្រែងធនាគារកណ្តាលក្នុងការរក្សាស្ថិរភាពសន្ទនិយភាពហិរញ្ញវត្ថុ



*ប្រភព៖ Thomas Smith, Khmer Times ២០២១*

នៅពេលនិយាយអំពីវិស័យហិរញ្ញវត្ថុក្នុងពេលមានជំងឺរាតត្បាតចាប់តាំងពីឆ្នាំ ២០២០ ឯកឧត្តម **ជា ចាន់តូ** អគ្គទេសាភិបាលធនាគារជាតិ (NBC) បានមានប្រសាសន៍ថា ដើម្បីទប់ទល់ផលប៉ះពាល់អវិជ្ជមានលើប្រព័ន្ធធនាគារ និងដឹកនាំស្ថិរភាពហិរញ្ញវត្ថុក្នុងពេលមានជំងឺរាតត្បាត NBC បានអនុវត្តវិធានការផ្សេងៗ ដើម្បីផ្តល់សន្ទនិយភាពដល់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ដូច្នេះ ពួកគេអាចរក្សាលំហូរឥណទានក្នុងការគាំទ្រដល់សកម្មភាពសេដ្ឋកិច្ច និងគ្រប់គ្រងហានិភ័យសន្ទនិយភាពរបស់ពួកគេ ក៏ដូចជាកាត់បន្ថយបន្ទុករបស់អ្នកខ្ចី ដែលជួបការលំបាកផ្នែកហិរញ្ញវត្ថុ ។

ឯកឧត្តម បានបន្តថា វិធានការណ៍ទាំងនោះ រួមមានការរក្សាបាននូវទ្រនាប់ដើមទុនឧនស៊ើវេសិន (Capital Conservation Buffer) ក្នុងអត្រា ១,២៥% និងការកាត់បន្ថយអត្រាការប្រាក់អប្បបរមា ស្តីពី ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ០,៥% សម្រាប់កាលកំណត់ទាំងអស់។ លើសពីនេះទៀត ឯកឧត្តមមានបំណងកាត់បន្ថយអនុបាតតម្រូវការប្រាក់បម្រុង (RRR) មកនៅត្រឹម៧% សម្រាប់រូបិយប័ណ្ណទាំងអស់ (ពី ៨% សម្រាប់ប្រាក់រៀល និង ១២,៥%សម្រាប់ប្រាក់ដុល្លារ) ហើយនិងអនុញ្ញាតឱ្យធនាគារ និងស្ថាប័នហិរញ្ញវត្ថុ រៀបចំរចនាសម្ព័ន្ធប្រាក់កម្ចីឡើងវិញ។

ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជា (NBC) ក៏បានពង្រឹងការអនុវត្តការត្រួតពិនិត្យដើម្បីឈានទៅមុខ និងពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃហានិភ័យនៅក្នុងប្រព័ន្ធធនាគារ រួមទាំងលើកកម្ពស់ប្រព័ន្ធទូទាត់ពីចម្ងាយ ដែលបានជួយគាំទ្រដល់សកម្មភាពសេដ្ឋកិច្ច និងការពារការរីករាលដាលនៃជំងឺរាតត្បាត ខណៈតម្លៃ និងអត្រាប្តូរប្រាក់មានស្ថិរភាព រក្សាទំនុកចិត្តសាធារណៈ ស្ថិរភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ប្រទេស។ ទន្ទឹមនឹងនេះ វិធានការដែលសម្រេចបានជោគជ័យកន្លងមកនោះ រួមមាន ការកាត់បន្ថយអនុបាតតម្រូវការប្រាក់បំរុង និងការកាត់បន្ថយអត្រាការប្រាក់ LPCO បានបង្កើតឱ្យមានសន្ទនិយភាពសាច់ប្រាក់ជាពិសេសប្រាក់រៀលនៅក្នុងប្រព័ន្ធធនាគារ។ ធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាចប្រើប្រាស់មូលនិធិនេះ ដើម្បីផ្តល់ប្រាក់កម្ចីកាន់តែច្រើនជាមួយនឹងអត្រាការប្រាក់ទាបជាងមុន។

ឯកឧត្តម បានបន្ថែមថា បច្ចុប្បន្នទុនបម្រុងអន្តរជាតិកម្ពុជា មានប្រហែល ២១ ប៊ីលានដុល្លារ ដែលអាចមានរយៈពេលស្មើ ១០ខែនៃការនាំចូល។ ក្រៅពីនេះ NBC បានធ្វើឱ្យប្រាកដថាប្រព័ន្ធធនាគារមានស្ថានភាពល្អ ដើម្បីធានានូវទំនុកចិត្តសាធារណៈ និងវិនិយោគិននៅក្នុងវិស័យហិរញ្ញវត្ថុ តាមរយៈការបង្កើតមូលដ្ឋានបទប្បញ្ញត្តិដ៏រឹងមាំ និងការពង្រឹងសមត្ថភាពត្រួតពិនិត្យធនាគារពីមួយពេលទៅមួយពេល។ ជាលទ្ធផល ប្រាក់បញ្ញើសរុបបានកើនឡើងដល់ ៣៧ប៊ីលានដុល្លារពីចំនួន ១៨០លានដុល្លារក្នុងឆ្នាំ១៩៩៨ ខណៈដែលមនុស្សពេញវ័យប្រហែល ៧០% អាចទទួលបានសេវា

កម្មហិរញ្ញវត្ថុ ដែលកាលពីជាង០២ទសវត្សរ៍មុន មានមិនដល់ ១០%ផង។ *ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ [Khmer Times]() ចេញផ្សាយថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១*

## តើកម្ពុជាអាចឈានទៅបើកប្រទេសទាំងស្រុងតាមផែនការកំណត់របស់រដ្ឋាភិបាលដែរ ឬយ៉ាងណា?



*រូបភាព៖ ហ្វេសប៊ុក អាកាសយានដ្ឋាន*

ខណៈដែលយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនប្រជាពលរដ្ឋចាប់ពីអាយុ១៨ឆ្នាំឡើងទៅសម្រេចបានជិត១០០% បានផ្តល់ក្តីសង្ឃឹមសម្រាប់កម្ពុជា ក្នុងការឈានទៅបើកសកម្មភាពសេដ្ឋកិច្ច និងសង្គមទាំងស្រុងក្នុងរយៈពេលដ៏ខ្លីខាងមុខ។

អ្នកសេដ្ឋកិច្ចនៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិ នៃរាជបណ្ឌិតសភាកម្ពុជា យល់ឃើញថា កម្ពុជាល្មមដល់ពេលត្រូវបើកសកម្មភាពសេដ្ឋកិច្ច និងសង្គមឡើងវិញហើយ បើពុំនោះទេវាអាចនឹងធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ និងសង្គមកាន់តែធ្ងន់ធ្ងរ បើបន្តបិទសកម្មភាពសេដ្ឋកិច្ច និងសង្គមដូចសព្វថ្ងៃ។

ប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជាបានមានប្រសាសន៍ថា គឺល្មមដល់ពេលហើយ ដែលកម្ពុជាត្រូវបើកប្រទេសទាំងមូលឡើងវិញ ដើម្បីស្តារសេដ្ឋកិច្ចឱ្យស្របតាមការព្យាករណ៍របស់ស្ថាប័នរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក ដែលបានបង្កើនការព្យាករណសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០២១ ចន្លោះពី១,៨% ទៅ ២,២%។ សេដ្ឋកិច្ចរបស់កម្ពុជាក្នុងឆ្នាំ២០២១ នឹងអាចកើនលើសការព្យាករនេះ ប្រសិនបើកម្ពុជាអាចបើកដំណើរការសកម្មភាពទេសចរណ៍ផ្ទៃក្នុង និងសកម្មភាពសេដ្ឋកិច្ចផ្សេងៗនៅពីរខែខាងមុខនេះ។ គម្រោងបើកសកម្មភាពសេដ្ឋកិច្ច និងសង្គមលើគ្រប់វិស័យឡើងវិញនេះ ត្រូវធ្វើឡើងតាមបែបគន្លងថ្មី ដោយបន្តអនុវត្តវិធានការ “៣កុំ និង៣ការពារ”ដែលដាក់ចេញដោយក្រសួងសុខាភិបាល។

បើយើងមើលទៅលើតួលេខអ្នកដែលបានចាក់វ៉ាក់សាំងរួចរាល់ គិតត្រឹមថ្ងៃទី១០ ខែតុលា ឆ្នាំ២០២១ កម្ពុជាសម្រេចបាន ៩៩,១៨%ហើយ លើយុទ្ធនាការចាក់វ៉ាក់សាំងជូនពលរដ្ឋអាយុចាប់ពី១៨ឆ្នាំឡើងទៅ។ ចំណែកអ្នកចាក់វ៉ាក់សាំងអាយុចាប់ពី១២ដល់១៧ឆ្នាំសម្រេចបានជាង៨៩%៕ *ដោយ ម៉ែន ខែមរៈ*

*[ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១]()*

## កសិករក្រើក្រប្រមាណ៩០០ គ្រួសារ នឹងទទួលបានពូជមាន់ កង្កែប និងត្រី ពីមន្ទីរកសិកម្មខេត្តឧត្តរមានជ័យ សហការជាមួយគម្រោងដៃគូ



*ដោយ ទៀជាតិកម្ពុជា*

ប្រជាពលរដ្ឋក្រីក្រ១ ក្រីក្រ២ និងបងប្អូនដែលត្រឡប់ពីចំណាកស្រុក មិនមានការងារធ្វើ ប្រមាណ ៩០០គ្រួសារ ទទួលបានពូជមាន់ ត្រី និងកង្កែប សម្រាប់ចិញ្ចឹមជា

លក្ខណៈគ្រួសារ ពីមន្ទីរកសិកម្មខេត្តឧត្តរមានជ័យ ជាមួយគម្រោងដៃគូនានា ដើម្បីលើកកម្ពស់ជីវភាព។

ដើម្បីរួមចំណែកលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ ធានាឱ្យបាននូវការទទួលបានស្បៀងអាហារ មន្ទីរកសិកម្មខេត្ត បានជួយដល់ប្រជាពលរដ្ឋក្រីក្រគ្រប់ប្រភេទ និងអ្នកដែលទើបត្រឡប់មកពីចំណាកស្រុកវិញ ទទួលបានជំនាញបច្ចេកទេសកសិកម្ម និងបានសហការជាមួយគម្រោងអង្គការដៃគូនានា ជួយជាសម្ភារកសិករ ពូជសត្វសម្រាប់យកទៅចិញ្ចឹមជាលក្ខណៈគ្រួសារ។ បច្ចុប្បន្ននេះ មន្ទីរកសិកម្មខេត្ត កំពុងអនុវត្តកម្មវិធីចំនួន ២ មានកម្មវិធីអាស្ប៉ាយ និងគម្រោងអង្គការជីអាយហ្សិត ដោយផ្តល់ពូជសត្វមាន់ កង្កែប ត្រី និងសម្ភារជាច្រើនទៀត។ គម្រោងនេះ ជាគម្រោងស្តារជីវភាព និងចិញ្ចឹមសត្វលក់។

ខណៈដែលវិបត្តិនៃជំងឺកូវីដ១៩ កំពុងតែបន្តរីករាលដាលនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ បានខិតខំប្រឹងប្រែងធ្វើយ៉ាងណា ដើម្បីចូលរួមបង្កើនផលិតភាពផលិតកម្មស្បៀង បង្កើតការងារ តាមរយៈការពង្រឹង និងពង្រីកសកម្មភាព ចិញ្ចឹមត្រី ចិញ្ចឹមកង្កែប ដាំដំណាំ និងបន្លែបង្ការជាលក្ខណៈគ្រួសារ ដើម្បីបង្កើនចំណូល ធានាសន្តិសុខស្បៀងក្នុងគ្រួសារ លើកកម្ពស់ជីវភាពគ្រួសារ ស្របពេលដែលវិស័យមួយចំនួនទៀតកំពុងប្រឈមបញ្ហាដោយសារជំងឺឆ្លងកូវីដ-១៩៕

*ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ក្រសួងព័ត៌មាន ចេញផ្សាយថ្ងៃទី១២ ខែតុលា ឆ្នាំ ២០២១*

## កិច្ចពិភាក្សាតុមូលថ្នាក់រដ្ឋមន្ត្រី ក្រោមប្រធានបទ ស្តីពី "ការប្រើប្រាស់បច្ចេកវិទ្យាទំនើប ដើម្បីវិបុលភាពរួម (Harnessing Frontier Technologies for Shared Prosperity )




*ប្រភព ៖ daily-khmer*

កាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០២១ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជាបានអញ្ជើញចូលរួមក្នុងកិច្ចពិភាក្សាតុមូលថ្នាក់រដ្ឋមន្ត្រី ក្រោមប្រធានបទស្តីពី "ការប្រើប្រាស់បច្ចេកវិទ្យាទំនើប ដើម្បីវិបុលភាពរួម( Harnessing Frontier Technologies for Shared Prosperity ) នៅសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី១៥ នៃសន្និសីទសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ ( UNCTAD 15 ) នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។ សន្និសីទនេះ គឺជាកិច្ចប្រជុំកំពូលរបស់អង្គការ UNCTAD ដែលធ្វើឡើងរយៈពេល៤ឆ្នាំម្តង ដោយមានការចូលរួមពីសមាជិកអង្គការ UNCTAD ទាំងអស់ ១៩៥ ប្រទេស និងអង្គការអន្តរជាតិ និងតួអង្គដទៃទៀត ដើម្បីពិភាក្សា និងរកដំណោះស្រាយដល់ការធ្វើពាណិជ្ជកម្ម និងការអភិវឌ្ឍន៍។

ឯកឧត្តមរដ្ឋមន្ត្រីបានថ្លែងថា ការផ្លាស់ប្តូរឌីជីថល ( Digital Transformation ) និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-commerce) បាន និងកំពុងជួយជំរុញផលិតភាព និងភាពប្រកួតប្រជែងរបស់សហគ្រាសមី

ក្រូ ធនតូច និងមធ្យម (MSMEs) ដែលជាឆ្អឹងខ្នងសេដ្ឋកិច្ចកម្ពុជា ហើយកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បាន និងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំ និងពង្រឹងគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងវិធានការ ពាក់ព័ន្ធនានា ដើម្បីពន្លឿនការអភិវឌ្ឍវិស័យនេះឱ្យបានជោគជ័យប្រកបដោយចីរភាព និងបរិយាបន្ន។ ការរីកចម្រើនយ៉ាងឆាប់រហ័សនៃពាណិជ្ជកម្ម និងសេដ្ឋកិច្ចឌីជីថល បានពង្រីកគម្លាតឌីជីថលរវាងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសអភិវឌ្ឍន៍តិចតួចឱ្យកាន់តែធំ។ ក្នុងន័យនេះ កិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ជាមួយប្រទេស ជាដៃគូពាណិជ្ជកម្ម ដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិពាក់ព័ន្ធនានា រួមមានអង្គការ UNCTAD មានតួនាទីសំខាន់ក្នុងការជួយគាំទ្រដល់ការអភិវឌ្ឍ និងការទទួលបានផលប្រយោជន៍ពីពាណិជ្ជកម្មឌីជីថល តាមរយៈការជួយកសាងហេដ្ឋារចនាសម្ព័ន្ធ ការផ្ទេរបច្ចេកវិទ្យា ការពង្រឹងប្រព័ន្ធច្បាប់ និងគោលនយោបាយ និងការអភិវឌ្ឍសមត្ថភាព ដើម្បីលើកកម្ពស់ភាពច្នៃប្រឌិត និងនវានុវត្តន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍តិចតួច។

នៅសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី១៤នៃសន្និសីទសហប្រជាជាតិ ស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ (UNCTAD 14) ដែលបានប្រព្រឹត្តទៅកាលពីឆ្នាំ ២០១៧ កម្ពុជាត្រូវបានជ្រើសរើសជាប្រទេសមួយសម្រាប់ធ្វើការវិភាគការត្រៀមខ្លួន ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក (e-Trade Readiness Assessment) ក្រោមការឧបត្ថមរបស់អង្គការ UNCTAD។ ការវិភាគនេះមានសារៈសំខាន់ក្នុងការចង្អុលបង្ហាញភាពខ្វះខាត និងបង្កើតជាផែនទីបង្ហាញផ្លូវមួយ ដើម្បីជំរុញការអភិវឌ្ឍវិស័យពាណិជ្ជកម្មតាមអេឡិចត្រូនិកនៅកម្ពុជា តាមរយៈគោលនយោបាយអភិវឌ្ឍន៍ ចំនួន ៧ រួមមាន គោលនយោបាយ និងយុទ្ធសាស្ត្រ, ហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្ម ICT, ការសម្របសម្រួល និងឡូជីស្ទីកពាណិជ្ជកម្ម, ដំណោះស្រាយលើការទូទាត់, ក្របខ័ណ្ឌនិងបទប្បញ្ញត្តិច្បាប់, ការអភិវឌ្ឍជំនាញ និងលទ្ធភាពក្នុងការទទួលបានហិរញ្ញវត្ថុ។

ជាលទ្ធផល ក្រសួងពាណិជ្ជកម្មបានដឹកនាំ និងចូលរួមការអភិវឌ្ឍ និងការធ្វើវិសោធនកម្ម ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនរួមមាន ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់, ច្បាប់ស្តីពី ការប្រកួតប្រជែង, ច្បាប់ស្តីពី បទល្មើសបច្ចេកវិទ្យាព័ត៌មាន, និងអនុក្រឹត្យស្តីពី ការគ្រប់គ្រង និងការលើកទឹកចិត្តធុរកិច្ចឌីជីថលថ្មី ជាដើម ក្នុងគោលបំណងដើម្បីគ្រប់គ្រង និងជំរុញការអភិវឌ្ឍ វិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងដោះស្រាយហានិភ័យផ្សេងៗពាក់ព័ន្ធទៅនឹងកិច្ចការពារទិន្នន័យ សន្តិសុខ និងបទល្មើសបច្ចេកវិទ្យាព័ត៌មាន កិច្ចការពារអ្នកប្រើប្រាស់ និងការប្រកួតប្រជែង។

រាជរដ្ឋាភិបាលកម្ពុជាមើលឃើញពីចក្ខុវិស័យវែងឆ្ងាយក្នុងការចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្ម ៤.០ ហើយបានរំលេចអំពី "ការរៀបចំខ្លួនសម្រាប់ការរីកចម្រើននៃសេដ្ឋកិច្ចឌីជីថល និងឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្ម៤.០" ក្នុងមុំទី៣ ចតុកោណទី២ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាល ទី៤។

ការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល ក៏ជាការឆ្លើយតបទៅនឹងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច តាមរយៈការលើកកម្ពស់សមត្ថភាព

របស់សហគ្រាសមីក្រូ ធុនតូច និងមធ្យមក្នុងស្រុកឲ្យផ្សារភ្ជាប់ទៅនឹងខ្សែសង្វាក់តម្លៃតំបន់ និងសកល។ រាជរដ្ឋាភិបាលកម្ពុជា ក៏បានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយ សេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥ ដែលនឹងរួមចំណែកយ៉ាងខ្លាំងក្នុងការស្តារ និងជំរុញសម្ទុះកំណើនសេដ្ឋកិច្ចថ្មី និងលើកកម្ពស់សុខុមាលភាពសង្គម តាមគន្លងប្រក្រតីថ្មីក្រោយពីវិបត្តិឆ្លងរាតត្បាតជាសកលនៃមេរោគកូវីដ-១៩។

ជាការឆ្លើយតបទៅនឹងគោលនយោបាយជាយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាល ក្រសួងពាណិជ្ជកម្ម ក្រោមការឧបត្ថម្ភហិរញ្ញប្បទានពីអង្គការក្របខ័ណ្ឌពង្រឹងសមាហរណកម្ម (EIF) បានរៀបចំយុទ្ធសាស្រ្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៅឆ្នាំ២០២០ ដើម្បីជាផែនទីបង្ហាញផ្លូវដល់ការអភិវឌ្ឍវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលជាវិស័យថ្មីមួយប្រកបដោយសក្តានុពលខ្ពស់ ក្នុងការបង្កើតប្រភពកំណើនថ្មីសម្រាប់សេដ្ឋកិច្ចកម្ពុជា។ យុទ្ធសាស្រ្តនេះ ត្រូវបានរៀបចំឡើងដោយមានលក្ខណៈប្រទាក់ក្រឡា និងឆ្លើយតបទៅនឹងអនុសាសន៍ដែលមានកំណត់ក្នុងឯកសារយុទ្ធសាស្រ្តទាក់ទងនឹងវិស័យពាណិជ្ជកម្មផ្សេងៗទៀត រួមមានឯកសារយុទ្ធសាស្រ្ត សមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ ២០១៩-២០២៣ ដើម្បីផ្តល់គំរូអាជីវកម្មថ្មីមួយប្រកបដោយប្រសិទ្ធភាព និងភាពប្រកួតប្រជែងខ្ពស់ ក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដែលមានលក្ខណៈសមស្របទៅនឹងបរិបទសេដ្ឋកិច្ចឌីជីថល និងលក្ខខណ្ឌតម្រូវការទីផ្សារក្នុងស្ថានភាពវិបត្តិជំងឺកូវីដ១៩ និងក្រោយវិបត្តិនេះផងដែរ។

ក្រសួងពាណិជ្ជកម្ម ក៏បានដាក់ចេញនូវគម្រោង Go4eCAM ក្រោមការឧបត្ថម្ភហិរញ្ញប្បទានពីអង្គការក្របខ័ណ្ឌពង្រឹងសមាហរណកម្ម (EIF) តាមរយៈជំនួយម្រាប់ពាណិជ្ជកម្ម (Aide for Trade) និងអង្គការ UNDP ក្នុងគោលបំណងដើម្បីទទួលបានផលប្រយោជន៍ពីការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយសហគ្រាសមីក្រូ ធុនតូច និងមធ្យម ជាពិសេសសហគ្រាសដឹកនាំដោយស្រ្តី និងយុវជន។ គម្រោងនេះនឹងផ្តល់ជូននូវអត្ថប្រយោជន៍ផ្សេងៗជាច្រើនទៀតរួមមាន ការទាញយកផលប្រយោជន៍ពីទីផ្សារអនឡាញប្រភេទ B2B2C ការបង្កើនផលិតភាព ភាពច្នៃប្រឌិត និងនវានុវត្តន៍ ពង្រីកអាជីវកម្ម និងបង្កើតការងារថ្មីៗនៅកម្ពុជា។

ក្រៅពីនេះ កម្ពុជាក៏បានចូលរួមចរចាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុង កិច្ចព្រមព្រៀង ពាណិជ្ជកម្មសេរីថ្នាក់តំបន់ និងទ្វេភាគី រួមមាន កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក របស់អាស៊ានជំពូក ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៃកិច្ចព្រមព្រៀងអាសិប និងជំពូកស្តីពី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន (CCFTA) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ (CKFTA) ។

សម្រាប់ក្របខ័ណ្ឌពហុភាគី កម្ពុជាក៏បានតាមដានយ៉ាងជិតដល់លើវឌ្ឍនភាពនៃគំនិតផ្តួចផ្តើមសេចក្តីថ្លែងការណ៍រួម ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ដែលកិច្ចព្រមព្រៀងទាំងនេះ នឹងធ្វើឱ្យវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់កម្ពុជាកាន់តែស៊ីជម្រៅបានមួយកម្រិតទៀត៕ *ដោយ ម៉ែន ខេមរៈ*

*ប្រភព៖daily-khmer ចេញផ្សាយថ្ងៃទី ១១ ខែតុលា ឆ្នាំ២០២១*

# តារាងប្រចាំសប្តាហ៍

## រូបភាពទី១៖ ការប្រៀបធៀបការអនុវត្តចំណូលថវិកាថ្នាក់ជាតិ ក្នុងខែសីហា ឆ្នាំ២០២១




រូបភាពទី១ ខាងលើនេះ បង្ហាញពីការប្រៀបធៀបការប្រមូលចំណូល ក្នុងខែសីហា ឆ្នាំ២០២១ ដែលរដ្ឋបាលថ្នាក់ជាតិអនុវត្តបាន។ ចំណូលក្នុងប្រទេសសរុបមានចំនួន ១ ៣៨០ ប៊ីលានរៀល ឬកើន ១% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០ ដែលមានចំនួនប្រមាណ ១ ៣៦៤ ប៊ីលានរៀល។ ក្នុងនោះ ចំណូលពន្ធលើប្រាក់បៀវត្ស មានចំនួនប្រហែល ៨៩% បើធៀបនឹងខែសីហា ឆ្នាំ២០២០។

គិតត្រឹមរយៈពេល ៨ខែ នៃឆ្នាំ២០២១ រដ្ឋបាលថ្នាក់ជាតិប្រមូលចំណូលក្នុងប្រទេសសរុប បានសម្រេចតាមផែនការគ្រោង ដែលមានចំនួនប្រហែល ១៣ ៤៣៩ ប៊ីលានរៀល ឬស្មើនឹង៦៧% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ខណៈ ដែលការអនុវត្តក្នុងរយៈពេលដូចគ្នា ឆ្នាំ២០២០ សម្រេចបានត្រឹមតែ ៥៨% នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២០។ បើទោះបីជាវិបត្តិជំងឺកូវិដ-១៩ បាននិងកំពុងបន្តដាក់សម្ពាធដល់ការប្រមូលចំណូលថវិកាជាតិ ក្នុងឆ្នាំ២០២១ ក៏ដោយ ក៏ការប្រមូលចំណូលថ្នាក់ជាតិនៅរក្សាបានស្ថិរភាពល្អ។ ***ដោយ ឈន ហាំ***

*ប្រភព៖ ការអនុវត្តថវិការដ្ឋ ខែធ្នូ ឆ្នាំ២០២០ និងការអនុវត្តថវិការដ្ឋ ខែសីហា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១*

## រូបភាពទី២៖ ការប្រៀបធៀបការអនុវត្តចំណាយថវិកាថ្នាក់ជាតិ ខែសីហា ឆ្នាំ២០២១




រូបភាពទី២ ខាងលើនេះ បង្ហាញពីការប្រៀបធៀបការអនុវត្តចំណាយថវិកា ក្នុងខែសីហា ឆ្នាំ២០២១ ដែលរដ្ឋបាលថ្នាក់ជាតិអនុវត្តបាន។ ចំណាយសរុបថ្នាក់ជាតិមានចំនួនប្រមាណ ២ ៤២២ ប៊ីលានរៀល ឬកើនឡើង ៣៧% បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២០ ដែលមានចំនួនប្រហែល ១ ៧៧៤ ប៊ីលានរៀល។ កំណើននេះដោយសារការរឹតបន្តឹងចំណាយមិនចាំបាច់ និងការបង្វែរមុខសញ្ញាអនុវត្តឱ្យចំគោលដៅ ប្រកបដោយបុរេសកម្ម សំដៅបន្តដោះស្រាយផលប៉ះពាល់នៃវិបត្តិជំងឺកូវិដ-១៩ ឱ្យបានទាន់ពេលវេលា។ ជាក់ស្តែង ក្នុងរយៈពេល ៨ខែ

នៃឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជាបានចំណាយលើអត្ថប្រយោជន៍សង្គម រហូតដល់ ២ ១៦១ ប៊ីលានរៀល ឬស្មើនឹង ២១% ដែលក្នុងនោះ ចំណាយលើជំនួយសង្គមដល់ប្រជាពលរដ្ឋលើអាហារនិងសម្ភារៈ និងជំនួយសង្គមផ្សេងៗអនុវត្តបាន ២៤១% និង ២៤៤% រៀងគ្នា នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២១។

គិតត្រឹមរយៈពេល ៨ខែ នៃឆ្នាំ២០២១ ការអនុវត្តចំណាយសម្រេចបានទាបជាងផែនការគ្រោងបន្តិច ដែលមានចំនួន ១៥ ៩០៦ ប៊ីលានរៀល ឬស្មើនឹង ៥៤% នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២១៕ *ដោយ ឈន ហាំ*

*ប្រភព៖ ការអនុវត្តថវិការដ្ឋ ខែធ្នូ ឆ្នាំ២០២០ និងការអនុវត្តថវិការដ្ឋ ខែសីហា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ពាណិជ្ជកម្មរបស់ម៉ាឡេស៊ីនៅក្នុងខែសីហា ឆ្នាំ២០២១ (គិតជាពាន់លានរីងហ្គីត)

ប្រតិបត្តិការពាណិជ្ជកម្មរបស់ប្រទេសម៉ាឡេស៊ីនៅតែមានភាពធន (resilient) និងរក្សាសន្ទុះកើននៅក្នុងខែសីហា ឆ្នាំ២០២១។ ពាណិជ្ជកម្មប្រទេសនេះបានកើនឡើង ១៥,៧% ស្មើនឹង ១៦៩,៧៩ ពាន់លានរីងហ្គីត ធៀបទៅនឹងខែសីហា ឆ្នាំ២០២០ ដែលមានកំណើនពីរខ្ទង់សម្រាប់រយៈពេលប្រាំពីរខែជាប់ៗគ្នា ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០២១។

កំណើននៃការនាំចេញមានការរួមចំណែកជាចម្បងដោយសារតម្រូវការខាងក្រៅដ៏រឹងមាំសម្រាប់ផលិតផលប្រេង ផលិតផលអគ្គិសនី និងអេឡិចត្រូនិក ភាគច្រើនដោយសារការនាំចេញនូវវត្ថុពាក់កណ្តាលចម្លង (semi-conductor) ព្រមទាំងសារធាតុគីមី និងផលិតផលគីមី។ ការនាំចេញទៅកាន់ទីផ្សារធំៗទាំងអស់ ដូចជាអាស៊ាន ចិន សហរដ្ឋអាមេរិក សហភាពអឺរ៉ុប និងជប៉ុន បានកត់ត្រាកំណើនវិជ្ជមាន។

ជារួម ប្រទេសម៉ាឡេស៊ីមានអតិរេកពាណិជ្ជកម្មចំនួន ៤៤,៧% ស្មើនឹង២១,៣៩ ពាន់លានរីងហ្គីតសម្រាប់ខែសីហា ឆ្នាំ២០២១នេះ៕ *ដោយ ធីម ប៊ុនធឿន*

| | ទំហំជួញដូរ |
|---|---|
| ការនាំចូល | ៩៥,៥៩ |
| ការនាំចេញ | ៧៤,២០ |
| តុល្យភាពពាណិជ្ជកម្ម | ២១,៣៩ |

*ប្រភព៖ matrade.gov.*

### ឱនភាពពាណិជ្ជកម្មវៀតណាម សម្រាប់ពាក់កណ្តាលចុងខែ នៃខែសីហា ឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)

យោងតាមស្ថិតិគយប្រទេសវៀតណាមបានបង្ហាញថា ការនាំចូលសរុបរបស់ប្រទេសវៀតណាម មានចំនួន ១៥,៨៧ ពាន់លានដុល្លារ ខណៈការនាំចេញមានចំនួន ១៤,៦២ ពាន់លានដុល្លារ។ ដូច្នេះ ប្រទេសវៀតណាមមានអតិរេកពាណិជ្ជកម្មចំនួន ១,២៥ ពាន់លានដុល្លារ សម្រាប់រយៈពេលពាក់កណ្តាលខែចុងក្រោយ នៃខែសីហា ឆ្នាំ២០២១។

បើធៀបទៅនឹងពាក់កណ្តាលខែដំបូង នៃខែសីហា ឆ្នាំ២០២១ ការនាំចេញបានកើនឡើង ៣៩,៦% ស្មើនឹង ៤,៥ ពាន់លានដុល្លារ។ កំណើននេះ មានការចូលរួមពីការនាំចេញកុំព្យូទ័រ និងផលិតផលគ្រឿងអេឡិចត្រូនិក ចំនួន ៦២,៣% ស្មើនឹង ១ ពាន់លានដុល្លារ ទូរស័ព្ទដៃ និងគ្រឿងបន្លាស់ ចំនួន ៣៧,៨% ស្មើនឹង ៨៨៣ លានដុល្លារ ដែកនិងដែកថែបចំនួន ៩១,៩% ស្មើ

នឹង ៤៦២ លានដុល្លារ ឧបករណ៍ម៉ាស៊ីន និងគ្រឿងបរិក្ខា ចំនួន ២៧,២% ស្មើនឹង ៣៧៥ លានដុល្លារ។

ដោយឡែក ការនាំចូលបានកើនឡើង ១៤,៨% ធៀបទៅនឹង ពាក់កណ្តាលខែដំបូង នៃខែសីហា ឆ្នាំ២០២១ ដែលឆ្លុះបញ្ចាំងពីការកើនឡើង នៃការនាំចូលកុំព្យូទ័រនិងផលិតផលអគ្គិសនីចំនួន ២៦,៥% ស្មើនឹង ៧៦៤ លានដុល្លារ ដែកនិងដែកថែបចំនួន ២៤,៦% ស្មើនឹង ១៣២ លានដុល្លារ ទូរស័ព្ទដៃចំនួន ២៣,៩% ស្មើនឹង ២០០ លានដុល្លារ ឧបករណ៍ម៉ាស៊ីន និងគ្រឿងបរិក្ខាចំនួន ៩,១% ស្មើនឹង ១៧៤ លានដុល្លារ។ *ដោយ ធឹម ប៊ុនធឿន*

| | ទំហំជួញដូរ |
|---|---|
| ការនាំចូល | ១៥,៨៧ |
| ការនាំចេញ | ១៤,៦២ |
| តុល្យភាពពាណិជ្ជកម្ម | ១,២៥ |

*ប្រភព៖ Vietnam Customs*

## រដ្ឋមន្ត្រីនៃក្រសួងហិរញ្ញវត្ថុឥណ្ឌូនេស៊ី មើលឃើញឱនភាពថវិកាឆ្នាំ២០២១ ទាបជាង៥,៤%នៃផលិតផលក្នុងស្រុកសរុប




*ប្រភព៖ TheStar, 2021 រូបភាព៖ Jakarta Post*

យោងតាមការលើកឡើងរបស់រដ្ឋមន្ត្រីនៃក្រសួងហិរញ្ញវត្ថុ លោកជំទាវ Sri Mulyaniបានបញ្ជាក់ថាឱនភាព ថវិកាសារពើពន្ធរបស់ឥណ្ឌូនេស៊ី អាចរួមតូចជាង ៥,៤% នៃ ផ.ស.សនៅឆ្នាំនេះដោយសារការរីកចំរើននៃទំនិញនិង ការងើបឡើងវិញនៃសេដ្ឋកិច្ច បន្ទាប់ពីរលកនៃជំងឺកូវីដ-១៩។

ការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចរបស់ប្រទេសឥណ្ឌូនេស៊ី បានកើនឡើងចាប់តាំងពីចុងខែសីហា បន្ទាប់ពីករណីឆ្លង នៃជំងឺកូវីដ-១៩ បានចាប់ផ្តើមធ្លាក់ចុះបន្ទាប់ពីមានការ កើនឡើងយ៉ាងខ្លាំងកាលពីខែកក្កដា។

រាជរដ្ឋាភិបាលបានបង្កើនថវិកាសង្គ្រោះវិបត្តិនៃជំងឺកូវីដ-១៩ របស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងករណីកើនឡើង ដែលជាហេតុធ្វើឱ្យទស្សនវិស័យឱនភាពថវិកាឆ្នាំ ២០២១ ពីមុនគឺមានអត្រា ៥,៨២% នៃផ.ស.ស។ សភារបស់ ប្រទេសឥណ្ឌូនេស៊ីក៏បានអនុម័តច្បាប់មួយផងដែរសម្រាប់ ការកែប្រែពន្ធដែលមានមហិច្ឆតាបំផុតរបស់ប្រទេសនេះ រួមទាំងការដំឡើងអាករលើតម្លៃបន្ថែមនៅឆ្នាំក្រោយ ពន្ធកាបូនថ្មី និងលុបចោលផែនការកាត់បន្ថយពន្ធសាជីវកម្ម។ ច្បាប់នេះមានគោលបំណងបង្កើនការប្រមូលចំណូល និង ធ្វើឱ្យប្រសើរឡើងនូវការបង់ពន្ធ បន្ទាប់ពីថវិកាសន្សំរបស់រដ្ឋត្រូវបានចំណាយយ៉ាងខ្លាំងនៅឆ្នាំនេះ និងនៅឆ្នាំ ២០២០ ដោយសារតែជំងឺរាតត្បាតកូវីដ -១៩ ។

ស្របពេលជាមួយគ្នានេះ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុបាន បញ្ជាក់បន្ថែមផងដែរថា៖ វិធានការសារពើពន្ធថ្មីនេះ នឹងបង្កើនចំណូលពន្ធនៅឆ្នាំក្រោយប្រមាណ ១៣៩,៣ ទ្រីលានរូពី (៩,៨ ប៊ីលានដុល្លារ) ដែលនឹងធ្វើឱ្យចំណូល នៃប្រទេសដែលមានសេដ្ឋកិច្ចធំបំផុតរបស់អាស៊ីអាគ្នេយ៍ កើនដល់ ៩,២២% នៃផ.ស.ស ពី ៨,៤៤% ដោយមិនទាន់ ប្រើច្បាប់ថ្មី។ ប៉ុន្តែក្រុមពាណិជ្ជកម្មនិងអ្នកវិភាគមួយចំនួន បានចោទសួរអំពីពេលវេលានៃការដំឡើងពន្ធនេះដោយ

ការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចពីជំងឺរាតត្បាតត្រូវបានគេមើលឃើញថាមានភាពផុយស្រួយ។

ច្បាប់នេះទាមទារឱ្យមានអាករលើតម្លៃបន្ថែម (VAT) សម្រាប់ការលក់ទំនិញនិងសេវាកម្មស្ទើរតែទាំងអស់ត្រូវតម្លើងពី ១០%ទៅដល់ ១១% នៅខែមេសាឆ្នាំក្រោយនិង ១២% នៅឆ្នាំ ២០២៥។ ច្បាប់នេះក៏នឹងលុបចោលផែនការនៃការកាត់ពន្ធសាជីវកម្ម និងដាក់ចេញអត្រាពន្ធលើប្រាក់ចំណូលខ្ពស់សម្រាប់បុគ្គលដែលមានទ្រព្យសម្បត្តិ ពន្ធកាបូនថ្មី និងកម្មវិធីលើកលែងពន្ធថ្មី។

តាមរយៈច្បាប់គឺចង់ធ្វើឱ្យប្រសើរឡើងនូវប្រាក់ចំណូលរបស់រដ្ឋាភិបាល បង្កើតប្រព័ន្ធពន្ធត្រឹមត្រូវជាងមុន ក៏ដូចជាពង្រីកមូលដ្ឋានពន្ធរបស់ប្រទេសនៅក្នុងយុគសម័យភាវូបនីយកម្មនេះស្របពេលដែលបច្ចេកវិទ្យាឌីជីថលលេចធ្លោខ្លាំង។ វិធានការពន្ធថ្មីនេះនឹងបន្ថែមតិចជាង ០,៥ ពិន្ទុភាគរយទៅនឹងអតិផរណា និងមានផលប៉ះពាល់តិចតួចដល់កំណើនសេដ្ឋកិច្ច។ *ដោយ សេន ចន្ទី*

*ប្រភព៖TheStar, ចេញផ្សាយថ្ងៃទី១១ខែតុលា ឆ្នាំ២០២១*

## ភាគហ៊ុនផ្នែកបដិសណ្ឋារកិច្ច និងការធ្វើដំណើរ កើនឡើងស្របផែនការនៃការបើកដំណើរការឡើងវិញរបស់ថៃ



*ប្រភព៖ bangkokpost, 2021 រូបភាព៖ Tourism Authority*

យោងតាមសេចក្តីប្រកាសរបស់នាយករដ្ឋមន្ត្រីប្រទេសថៃបានឱ្យដឹងថា៖ ភ្ញៀវទេសចរដែលបានចាក់វ៉ាក់សាំងគ្រប់ចំនួននឹងត្រូវបានអនុញ្ញាតឱ្យមកទស្សនាប្រទេសថៃចាប់ពីខែវិច្ឆិកា បន្ទាប់ពីប្រទេសថៃបានដាក់វិធានការណ៍រឹតត្បិតអស់រយៈពេលជាង១៨ខែ ហើយការរឹតត្បិតនេះនឹងត្រូវបញ្ចប់នៅខែក្រោយ សម្រាប់ការមកដល់របស់ភ្ញៀវដែលបានចាក់វ៉ាក់សាំង ហើយមកពីប្រទេសដែលចាត់ទុកថាមានហានិភ័យទាប រួមទាំងសហរដ្ឋអាមេរិក អង់គ្លេស និងចិន។

សន្ទស្សន៍នៃទីផ្សារភាគហ៊ុនផ្នែកទេសចរណ៍និងការកំសាន្តបានកើនឡើង ៤,៤២% នៅពេលដែលទីផ្សារភាគហ៊ុនបានបើកដំណើរការឡើងវិញ ដែលធ្លាប់បានរំពឹងថានឹងកើនឡើងត្រឹម ០,៨២%។

ការកើនឡើងនេះត្រូវបានជំរុញដោយការកើនឡើងសន្ទស្សន៍នៃផ្សារភាគហ៊ុន ៤% នៃព្រលានយន្តហោះថៃភីអិលស៊ី ហើយក្រុមហ៊ុនអាកាសចរណ៍អាស៊ី និងក្រុមហ៊ុនអាកាសចរណ៍បាងកកកើនឡើង ៥,៥៩% និង ៣,៤២% រៀងៗគ្នា។ ចំណែក Hotelier Erawan Group Plc កើនឡើងជិត ៧% ហើយគូប្រជែង Asset World Corp បានកើនឡើងជាង ៤%។

ការដាក់ចេញនូវវិធានការណ៍តឹងរ៉ឹងរបស់រដ្ឋាភិបាលបានធ្វើឱ្យចំនួនអ្នកឆ្លងជំងឺកូវីដ-១៩ មានកម្រិតទាបរហូតដល់ឆ្នាំនេះ ប៉ុន្តែបានខាតបង់យ៉ាងច្រើនចំពោះការងារនិងប្រាក់ចំណូលនៅក្នុងវិស័យទេសចរណ៍ដ៏សំខាន់របស់ខ្លួន។ ចាប់តាំងពីខែកក្កដាមកប្រទេសថៃបានបើកដំណើរការគម្រោងសាកល្បងនៅលើកោះសាមុយនិងភូកេតដែលអនុញ្ញាតឱ្យអ្នកចាក់វ៉ាក់សាំងហើយ ប៉ុន្តែការមកដល់នៃភ្ញៀវទេសចរបានធ្លាក់ចុះ ដល់ ៨២% បន្ទាប់ប្រទេសនេះធ្លាប់ទទួលភ្ញៀវទេសចររហូតដល់ ជិត ៤០ លាននាក់ក្នុង

ឆ្នាំ ២០១៩ ជាមួយនឹងចំណូល ៥០ ប៊ីលានដុល្លារក្នុងមួយឆ្នាំ ។ ថ្វីបើមានវិធានការតឹងរ៉ឹងដើម្បីការពារជំងឺនេះក៏ដោយ ប្រទេសនេះមានកំណត់ត្រាការឆ្លងចំនួន ១,៧ លាននាក់ និងការស្លាប់ចំនួន ១៧ ៨៣៥ នាក់នៃកូវីដ-១៩ ដែលចំនួន ៩៨% នៃការឆ្លង និងស្លាប់សរុប គឺមានចាប់តាំងពីខែមេសាមក។ មួយភាគបីនៃប្រជាជន ៧២ លាននាក់របស់ប្រទេសថៃត្រូវបានចាក់វ៉ាក់សាំងរួចរាល់។

ការប្រកាសនេះធ្វើឡើងបន្ទាប់ពីចក្រភពអង់គ្លេសដកប្រទេសថៃចេញពីបញ្ជីក្រហមហាមឃាត់ធ្វើដំណើររបស់ខ្លួនកាលពីសប្តាហ៍មុន។ ក្រុមអ្នកវិភាគបាននិយាយថា ទោះបីជាមានការមកដល់របស់ភ្ញៀវបរទេស អាចនឹងមិនកើនឡើងយ៉ាងឆាប់រហ័សក៏ដោយ ក៏សកម្មភាពក្នុងស្រុកនឹងត្រូវបានជំរុញ៕ *ដោយ សេន ចន្ទី*

*ប្រភព៖ bangkokpost, ចេញផ្សាយថ្ងៃទី១២ខែតុលា ឆ្នាំ២០២១*

## រោងចក្រកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង វៀតណាមជាង៦៨% ទទួលរងការលុបចោលការបញ្ជាទិញ និងពិន័យប្រាក់



*ប្រភព ៖ ខេមបូណ្ឌមីស*

សហគ្រាសកាត់ដេរ និងស្បែកជើងនៅវៀតណាមជាង ៦៨%ត្រូវបានរងការលុបចោលការបញ្ជាទិញ និងពិន័យជាសំណងពីអ្នកបញ្ជាទិញបរទេស ចំពោះការដឹកជញ្ជូនយឺតយ៉ាវ ដោយសារការបិទខ្ទប់ប្រទេស និងវិធានការគម្លាតសង្គម ដែលបង្កការរាំងស្ទះដល់ការដឹកជញ្ជូន។ ក្រុមហ៊ុនក្នុងស្រុក១២% ត្រូវបានអតិថិជនបរទេសលុបចោលការកម្ម៉ង់ទិញ និងទាមទារសំណងដោយសារតែរំលោភកិច្ចសន្យា និង២១%ទៀតត្រូវបានអតិថិជនក្រៅស្រុកលុបចោលការបញ្ជាទិញ ប៉ុន្តែមិនទារសំណង។

ជាធម្មតាការដឹកជញ្ជូនទំនិញពីអាស៊ីទៅអាមេរិកត្រូវចំណាយ៤០ថ្ងៃប៉ុណ្ណោះ តែក្រោយមានវិធានការគម្លាតសង្គមទំនិញទាំងនោះត្រូវចំណាយពេលរហូតដល់៨០ថ្ងៃ។ ហេតុដូចនេះហើយ ភាពយឺតយ៉ាវនេះបានធ្វើឱ្យអតិថិជនបរទេសមួយចំនួនបានផ្លាស់ប្តូរការបញ្ជាទិញទៅប្រទេសផ្សេងទៀត ហើយការផ្លាស់ប្តូរបែបនេះ អាចនឹងបន្តក្នុងរយៈពេល ៥ ខែទៅមុខទៀត។

ការនាំចេញសម្លៀកបំពាក់ និងវាយនភ័ណ្ឌវៀតណាមនៅក្នុងខែកញ្ញាធ្លាក់ចុះ៩% និងការនាំចេញស្បែកជើងក្នុងខែកញ្ញា ធ្លាក់ចុះជាង ៤៤% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុនខណៈពេលការនាំចេញកាបូបក៏បានធ្លាក់ចុះ ៤៨%ផងដែរ។ *ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១*

## សហភាពអឺរ៉ុប គ្រោងផ្តល់ជំនួយឥតសំណងជាង ១៧ លានដុល្លារ ដើម្បីអភិវឌ្ឍវិស័យកសិកម្មកម្ពុជា



*ដោយ ខេមបូណ្ឌមីស*

ធនាគារវិនិយោគអឺរ៉ុប(EIB) បានទទួលជំនួយឥតសំណងក្នុងទឹកប្រាក់ ១៥លានអឺរ៉ូ ឬស្មើនឹង ១៧,៤លាន

ដុល្លារ ពីសហភាពអឺរ៉ុប ដើម្បីអភិវឌ្ឍវិស័យកសិកម្ម កម្ពុជា។ គម្រោងនេះ មានឈ្មោះថា SAAMBAT ដែលជាគម្រោងគាំទ្រនិរន្តរភាពហេដ្ឋារចនាសម្ព័ន្ធជនបទ ដើម្បីទីផ្សារកសិករ និងពាណិជ្ជូបនីយកម្មកសិកម្ម នៅកម្ពុជា។

គម្រោង SAAMBAT ត្រូវបានរៀបចំឡើង ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវផ្លូវជនបទ ការតភ្ជាប់ទំនាក់ទំនងទូទាំងប្រទេស ការលើកកម្ពស់ភាពធន់នឹងគ្រោះធម្មជាតិ និងការឆ្លើយតបចំពោះបញ្ហាខ្វះស្បៀងតាមផ្លូវ។ ក្នុងពិធីចុះហត្ថលេខាផ្តល់ជំនួយឥតសំណង មានការចូលរួមពីលោក Kris Peeters អនុប្រធានធនាគារវិនិយោគអឺរ៉ុប(EIB) និងជាមន្ត្រីទទួលបន្ទុកប្រតិបត្តិការធនាគារ EIB នៅកម្ពុជា លោក Bryan Fornari ប្រធានសហប្រតិបត្តិការនៃប្រតិភូសហភាពអឺរ៉ុប ប្រចាំកម្ពុជា និងរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កម្ពុជា។ លោក Kris Peeters បានលើកឡើងថា EIB មានមោទនភាពយ៉ាងខ្លាំង ចំពោះការបន្តរួមចំណែកក្នុងការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជាពីជំងឺរាតត្បាតកូវីដ-១៩ និងផ្តល់ការអភិវឌ្ឍបៃតងប្រកបដោយនិរន្តរភាព និងយូរអង្វែងផងដែររបស់ប្រទេសកម្ពុជា។ នេះ គឺជាជំហានមួយទៀត ឆ្ពោះទៅរកភាពជាដៃគូកាន់តែជិតស្និទរវាងសហភាពអឺរ៉ុប និងកម្ពុជា ហើយសំខាន់ជាងនេះ គម្រោងនេះនឹងជះឥទ្ធិពលផ្ទាល់ទៅលើគុណភាពជីវិតរបស់ប្រជាជនកម្ពុជា រាប់សែននាក់។

ភាគីកម្ពុជា បានចាត់ទុកថា ជំនួយឥតសំណងនេះ គឺជាការរួមចំណែកយ៉ាងសំខាន់ដល់ការពន្លឿនការអភិវឌ្ឍន៍ដោយចីរភាពនៃសហគមជនបទ នៅកម្ពុជា ក៏ដូចជា ការស្តារឡើងវិញពីការរាតត្បាតសាកលនៃការឆ្លងរាលដាលជំងឺកូវីដ-១៩។ គម្រោងនេះនឹងចូលរួមលើកកម្ពស់ជីវភាពប្រជាពលរដ្ឋនៅតាមទីជនបទ និងបង្កើតការងារ សម្រាប់យុវជន និងការបង្កើតសហគ្រាសខ្នាតតូច និងមធ្យមថ្មី ទូទាំងប្រទេសកម្ពុជា៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១*

## សេដ្ឋកិច្ចសកល

### បំណុលរបស់ប្រទេសក្រីក្រកើនឡើង ១២% ស្មើនឹង ៨៦០ប៊ីលានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០២០ យោងតាមធនាគារពិភពលោក



*ប្រភព៖ Reuters ២០២១, រូបភាព៖ Mike Theiler/Files*

ធនាគារពិភពលោក បានព្រមានពីការកើនឡើងយ៉ាងគំហុកនៃបំណុលរបស់បណ្តាប្រទេសដែលមានប្រាក់ចំណូលទាបនៅលើពិភពលោក ជាមួយនឹងកំណើន ១២% ស្មើនឹង ៨៦០ប៊ីលានដុល្លារអាមេរិកក្នុងឆ្នាំ២០២០ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ និងបានអំពាវនាវឱ្យមានកិច្ចខិតខំប្រឹងប្រែងជាបន្ទាន់ ដើម្បីកាត់បន្ថយកម្រិតបំណុល នេះបើយោងតាមរបាយការណ៍ស្ថិតិបំណុលអន្តរជាតិថ្មីឆ្នាំ២០២២ ដែលទើបចេញផ្សាយនាពេលថ្មីៗរបស់ខ្លួន។

ជាមួយគ្នានេះដែរ យោងតាមសម្តីរបស់លោក David Malpass ប្រធានធនាគារពិភពលោក បានឱ្យដឹងថា

មានការកើនឡើងយ៉ាងខ្លាំងនៃការប្រឈមនឹងហានិភ័យបំណុលនៅក្នុងប្រទេសដែលមានចំណូលទាប និង ចំណូលមធ្យម ខណៈ ពាក់កណ្តាលនៃប្រទេសក្រីក្របំផុតនៅលើពិភពលោក បានស្ថិតនៅក្នុងបញ្ហាបំណុលក្រៅប្រទេស ឬហានិភ័យខ្ពស់ ហើយលោកក៏បានជំរុញឱ្យការខិតខំប្រឹងប្រែងយ៉ាងទូលំទូលាយ ដើម្បីជួយប្រទេសទាំងនោះអាចគ្រប់គ្រងចីរភាពបំណុល ដើម្បីស្តារសេដ្ឋកិច្ចឡើងវិញនិងកាត់បន្ថយភាពក្រីក្រ។

លោក Malpass បានបន្ថែមថា «យើងត្រូវការវិធីសាស្រ្តដ៏ទូលំទូលាយមួយចំពោះបញ្ហាបំណុលនេះ ដែលរួមមានការកាត់បន្ថយបំណុល ការរៀបចំរចនាសម្ព័ន្ធបំណុលឡើងវិញឱ្យបានឆាប់រហ័ស និងការបង្កើនតម្លាភាព»។

ទន្ទឹមនឹងនេះ កិច្ចខិតខំប្រឹងប្រែងរៀបចំរចនាសម្ព័ន្ធបំណុលឡើងវិញជាតម្រូវការយ៉ាងចាំបាច់ជាបន្ទាន់ ដោយសារវិធានការគំនិតផ្តួចផ្តើមព្យួរសេវាកម្មបំណុល (Debt Service Suspension Initiative) របស់ក្រុមប្រទេសសេដ្ឋកិច្ចនាំមុខ G20 ដែលបានផ្តល់ការពន្យារពេលបណ្តោះអាសន្ននៃការទូទាត់បំណុលនឹងផុតកាលកំណត់នៅចុងឆ្នាំនេះ។ បន្ថែមពីនេះ ការបង្អកការទូទាត់បំណុលបន្ថែមទៀតអាចត្រូវបានរួមបញ្ចូល ដែលជាផ្នែកនៃក្របខណ្ឌរួមការរៀបចំរចនាសម្ព័ន្ធបំណុល ប៉ុន្តែការងារបន្ថែមទៀតគឺត្រូវបង្កើនការចូលរួមពីម្ចាស់បំណុលក្នុងវិស័យឯកជន ដែលរហូតមកដល់ពេលនេះនៅតែមានការស្ទាក់ស្ទើរក្នុងការចូលរួម។

របាយការណ៍បានបង្ហាញនូវសន្និធិបំណុលក្រៅប្រទេសរបស់ប្រទេសដែលមានចំណូលទាប និងចំណូលមធ្យម ដោយរួមបញ្ចូលគ្នាកើនឡើង ៥,៣% ដល់ ៨,៧ទ្រីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០២០ ដែលនេះកំពុងជះឥទ្ធិពលដល់ប្រទេសទាំងអស់នៅក្នុងតំបន់។

កំណើននៃបំណុលក្រៅប្រទេសបានកើនឡើងលើសចំណូលជាតិសរុប (GNI) និងកំណើននៃការនាំចេញ ដោយអនុបាតបំណុលក្រៅប្រទេសធៀបនឹង GNI (external debt-to-GNI ratio) ដោយមិនរាប់បញ្ចូលប្រទេសចិនបានកើនឡើង ៥ពិន្ទុភាគរយ ដល់ ៤២% ក្នុងឆ្នាំ២០២០ ខណៈដែលអនុបាតបំណុលក្រៅប្រទេសធៀបនឹងការនាំចេញ (debt-to-export ratio) បានកើនឡើងដល់ ១៥៤% ក្នុងឆ្នាំ២០២០ ពី ១២៦% ក្នុងឆ្នាំ២០១៩។ ចំណែកឯលំហូរសាច់ប្រាក់សរុបពីម្ចាស់បំណុលពហុភាគីទៅកាន់ប្រទេសដែលមានចំណូលទាប និងចំណូលមធ្យម បានកើនឡើងដល់ ១១៧ប៊ីលានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០២០ ដែលជាកម្រិតខ្ពស់បំផុត ខណៈការផ្តល់កម្ចីសរុបដល់ប្រទេសដែលមានប្រាក់ចំណូលទាបបានកើនឡើង ២៥% ស្មើនឹង ៧១ប៊ីលានដុល្លារអាមេរិក ដែលជាកម្រិតខ្ពស់បំផុតក្នុងរយៈពេលមួយទសវត្សរ៍។ ក្នុងនោះម្ចាស់បំណុល រួមមាន IMF និងម្ចាស់បំណុលពហុភាគីផ្សេងទៀត បានផ្តល់កម្ចីចំនួន ៤២ប៊ីលានដុល្លារអាមេរិក និងម្ចាស់បំណុលទ្វេភាគីមានចំនួន ១០ប៊ីលានដុល្លារអាមេរិក។

យោងតាមសម្តីរបស់លោកស្រី Carmen Reinhart ប្រធានសេដ្ឋវិទូធនាគារពិភពលោក បញ្ហាប្រឈមខ្ពស់នៃប្រទេសកំពុងជំពាក់បំណុលគេអាចនឹងកាន់តែអាក្រក់ទៅៗ ដោយសារអត្រាការប្រាក់កើនឡើង៕

*ដោយ ស៊ិន សុភាព៌*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Reuters ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១*

## សេតវិមានអាមេរិក អំពាវនាវឱ្យ OPEC+ ធ្វើការបន្ថែមទៀតពាក់ព័ន្ធនឹងតម្លៃប្រេងឆៅ



*ប្រភព៖ Reuters ២០២១, រូបភាព៖ Leonhard Foeger*

សេតវិមានអាមេរិក បាន និងកំពុងអំពាវនាវដល់ប្រទេសផលិតប្រេងឱ្យ «ធ្វើការងារបន្ថែមទៀត» ដើម្បីគាំទ្រដល់ការស្តារឡើងវិញនៃសេដ្ឋកិច្ចសកល ដោយសារតម្លៃប្រេងឆៅបានហក់ឡើងដល់កម្រិតខ្ពស់បំផុតក្នុងរយៈពេលជាច្រើនឆ្នាំនេះ។

សេតវិមានកំពុងឃ្លាំមើលយ៉ាងជិតដល់ ចំពោះថ្លៃដើមប្រេងឆៅ និងប្រេងសាំង ព្រមទាំង «ប្រើប្រាស់គ្រប់មធ្យោបាយដែលអាចធ្វើទៅបានក្នុងការដោះស្រាយទប់ទល់នឹងការប្រេកួតប្រជែង នៅក្នុងទីផ្សារថាមពលអាមេរិក និងពិភពលោកដើម្បីធានាបាននូវទីផ្សារថាមពលដែលអាចទុកចិត្តបាន និងមានស្ថិរភាព»។

ជាក់ស្តែង តម្លៃប្រេងឆៅ Brent របស់អង់គ្លេសស្ថិតក្នុងកម្រិតមួយដែលមិនធ្លាប់មានចាប់តាំងពីឆ្នាំ២០១៨ ខណៈតម្លៃប្រេងឆៅរបស់សហរដ្ឋអាមេរិក West Texas Intermediate (WTI) ឡើងដល់កម្រិតខ្ពស់មិនធ្លាប់មានចាប់តាំងពីឆ្នាំ២០១៤ ដោយសារកត្តារួមផ្សំគ្នា។ ទោះយ៉ាងណា អង្គការ OPEC+ បានរក្សាដែនកំណត់លើការផ្គត់ផ្គង់ប្រេងរបស់ខ្លួនចាប់តាំងពីការផ្ទុះឡើងនៃជំងឺរាតត្បាតកូវីដ-១៩។ ខណៈនៅពេលមួយ ខ្លួនបានកាត់បន្ថយការផ្គត់ផ្គង់ប្រេងប្រចាំថ្ងៃជាង ១០លានបារ៉ែលពីទីផ្សារដោយសារតម្រូវការធ្លាក់ចុះ។ គិតត្រឹមខែកក្កដា ឆ្នាំ២០២១ អង្គការ OPEC+ បានយល់ព្រមបង្កើនទិន្នផលផលិតចំនួន ៤០០ ០០០បារ៉ែលក្នុងមួយថ្ងៃ ដើម្បីបញ្ឈប់នូវការបន្តកាត់បន្ថយការផលិតប្រេងចំនួន ៥,៨លានបារ៉ែលក្នុងមួយថ្ងៃ។

ដោយឡែក ផលិតកម្មប្រេងរបស់សហរដ្ឋអាមេរិកនៅតែទាបជាងកម្រិតដែលខ្លួនធ្លាប់បានផលិតក្នុងបរិមាណខ្ពស់ជិត ១៣លានបារ៉ែលក្នុងមួយថ្ងៃ នៅចុងឆ្នាំ២០១៩ បើទោះបីជាតម្រូវការប្រេងឥន្ធនៈប្រចាំថ្ងៃបានស្ទុះងើបឡើងដល់កម្រិតមុនពេលផ្ទុះជំងឺរាតត្បាតកូវីដ-១៩ ក្តី៕

*ដោយ ស៊ិន សុភ៉ា*

*ប្រភព៖គេហទំព័រ Reuters ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី១៨ ខែតុលា ឆ្នាំ២០២១

- កំណើនសេដ្ឋកិច្ចចិន ក្នុងត្រីមាសទី ៣ ឆ្នាំ ២០២១
- អត្រានិកម្មភាព នៅទីក្រុងរបស់ប្រទេសចិន នៅក្នុងខែសីហា មិនផ្លាស់ប្តូរ

ថ្ងៃអង្គារ ទី១៩ ខែតុលា ឆ្នាំ២០២១

- ឱនភាពពាណិជ្ជកម្មអេស្ប៉ាញ បានកើនឡើងយ៉ាងខ្លាំង ធៀបនឹងឆ្នាំមុន
- អត្រាការប្រាក់កម្ចីនៅឥណ្ឌូនេស៊ីនៅតែមិនផ្លាស់ប្តូរ នៅក្នុងខែកញ្ញា ឆ្នាំ ២០២១

ថ្ងៃពុធ ទី២០ ខែតុលា ឆ្នាំ២០២១

- ប្រទេសជប៉ុនបានបង្ហាញ ឱនភាពពាណិជ្ជកម្ម នៅខែសីហាឆ្នាំ ២០២១
- អត្រាអតិផរណាប្រចាំឆ្នាំនៅចក្រភពអង់គ្លេស បានកើនឡើង ក្នុងខែសីហាឆ្នាំ ២០២១

ថ្ងៃព្រហស្បតិ៍ ទី២១ ខែតុលា ឆ្នាំ២០២១

- សូចនាករទំនុកចិត្តអ្នកប្រើប្រាស់របស់ទួរគី បានកើនឡើង ក្នុងខែកញ្ញាឆ្នាំ ២០២១
- ការវិនិយោគភាគហ៊ុនដោយជនបរទេសនៅប្រទេសជប៉ុនបានថយចុះនាដើម ខែតុលាឆ្នាំ ២០២១

ថ្ងៃសុក្រ ទី២២ ខែតុលា ឆ្នាំ២០២១

- អតិរេកពាណិជ្ជកម្មរបស់អាហ្សង់ទីន បានកើនឡើង នៅខែសីហាឆ្នាំ ២០២១
- ធនាគារកណ្តាលនៃប្រទេសរុស្ស៊ីបានបង្កើនអត្រាគោលនយោបាយគោលរបស់ខ្លួន៕